ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៣...សហវ.....

ថតចម្លង

# សារាចរណែនាំ

## ស្តីពី

## ការគ្រប់គ្រងការនាំចេញ នាំចូលទំនិញមួយចំនួនតាមរូបភាពតូច

កន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសង្កេតឃើញនូវបាតុភាពអសកម្មមួយចំនួនដែលបង្កឡើងដោយក្រុមបុគ្គលខ្លះ តាមរយៈការបង្កើតនូវស្តង់ទំនិញតាមរូបភាពផ្សេងៗ រួចដំណើរការអាជីវកម្មស្រដៀងរូបភាពផ្តាច់មុខ និងប្រមូលកំរ៉ៃពីអ្នកនាំចេញ- នាំចូលផ្សេងទៀត បង្កជាឧបសគ្គដល់អាជីវករទាំងនោះ ជាពិសេសពាក់ព័ន្ធនឹងមុខទំនិញឆាប់ខូច ដូចជា បន្លែ ផ្លែឈើ មើមឈើ និងផលិតផលកសិកម្មឆាប់ខូចផ្សេងទៀតរបស់អាជីវករតូចតាច។

ក្នុងន័យនេះ ដើម្បីកាត់បន្ថយនូវបាតុភាពអសកម្មទាំងនេះ និងដោយយោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩ លើលិខិតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៦០៦១ សហវ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ ផងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការកំណត់ និងណែនាំជាបណ្តោះអាសន្នដល់គ្រប់អង្គភាពគយ និងរដ្ឋាករ និងបុគ្គលពាក់ព័ន្ធនានា ដូចខាងក្រោម :

១. ត្រូវបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់តាមបទបញ្ញត្តិច្បាប់ជាធរមាន ជាពិសេសសារាចរលេខ ០០៩ សហវ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម។

២. សេវាកម្មបំពេញបែបបទគយនាំចេញ- នាំចូលទំនិញជំនួសអ្នកដទៃ អាចធ្វើទៅបានតែដោយបុគ្គលដែលមានគុណវុឌ្ឍជាជើងសារគយណាមួយប៉ុណ្ណោះ តាមបញ្ញត្តិជំពូក ៥ នៃច្បាប់ស្តីពីគយ។ បុគ្គលជាជើងសារគយ អាចប្រមូលកំរ៉ៃពីម្ចាស់ទំនិញពិត ទៅតាមការព្រមព្រៀងគ្នាជាមុន តាមករណីជាក់ស្តែងនីមួយៗ។

៣. សម្រួលអនុគ្រោះជូនរូបវន្តបុគ្គល ដែលធ្វើអាជីវកម្មនាំចេញ- នាំចូលតាមរូបភាពតូច មានតម្លៃគិតពន្ធសមមូលត្រឹម ៣០០ ដុល្លារអាមេរិកចុះ លើមុខទំនិញមួយចំនួន រួមមាន បន្លែ ផ្លែឈើ និងកសិផលប្រហាក់ប្រហែលផ្សេងទៀត ដែលមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ និងបញ្ជីទំនិញជាប់កម្រិតកំណត់ ជាធរមាន អាចបំពេញបែបបទគយដោយខ្លួនឯងបាន ទោះបីមាន ឬគ្មានលេខអត្តសញ្ញាណកម្មអាករលើតម្លៃបន្ថែមក្តី ដោយគ្រាន់តែធ្វើប្រកាសសុំតាមទម្រង់សង្ខេបដូចមានជូនភ្ជាប់មកជាមួយនេះ និងតម្កល់នូវច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬឯកសារសំគាល់ខ្លួនផ្លូវការផ្សេងទៀត ដោយមានផ្តិតមេដៃស្តាំបញ្ជាក់ ព្រមទាំងចុះហត្ថលេខា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

ចំពោះមុខមន្ត្រីមានសមត្ថកិច្ចជាប់ជាមួយ។ ករណីដូចនេះ ត្រូវបានអនុគ្រោះសំរាប់ការនាំចូល- នាំចេញតាមរូបភាពតូចៗ ដើម្បីចរាចរចែកចាយក្នុងប្រទេសពាក់ព័ន្ធ ទោះបីមានលក្ខណៈពាណិជ្ជកម្មក្តី ហើយតម្លៃគិតពន្ធលើមុខទំនិញទាំងនេះ ត្រូវបានកំណត់ដោយបូកបន្ថែម ១០% លើតម្លៃគិតពន្ធគយតាមបទបញ្ញត្តិជាធរមានដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចនាមាត់ច្រកបំពេញបែបបទគយតែម្តង។

៤. ក្នុងករណីជួបប្រទះនូវការលំបាកនានាក្នុងពេលអនុវត្តតាមខ្លឹមសារខាងលើ ឬក្នុងករណីសង្កេតឃើញនូវបាតុភាពអសកម្មនានាបន្តទៀតនោះ បុគ្គលពាក់ព័ន្ធ ត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងដោះស្រាយជូនឱ្យបានទាន់ពេលវេលា។

ទទួលបានសារាចរណែនាំនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចាត់ចែងឱ្យមានការផ្សព្វផ្សាយទូលំទូលាយដល់អាជីវករតូចតាចដែលប្រកបរបរនាំចេញ- នាំចូលទំនិញដូចរៀបរាប់ខាងលើ ឱ្យបានយល់ពីនីតិវិធីសាមញ្ញនេះ ហើយជំរុញឱ្យមានការបំពេញកាតព្វកិច្ចពន្ធ អាករឱ្យបានត្រឹមត្រូវតាមបទបញ្ញត្តិច្បាប់ជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ រហូត ដល់មានការសម្រេចជាថ្មី។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- គ្រប់សាលារាជធានី- ខេត្ត

  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ

  "ដើម្បីជ្រាប និងអនុវត្តតាមមុខការ"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

បញ្ជិកាគយលេខ Customs Registration No. :............
កាលបរិច្ឆេទ Date:........./........../..........
ត្រាគយ Customs Stamp

## ប្រតិវេទន៍គយសង្ខេប "Summary Declaration" នាំចូល Import ☐ នាំចេញ Export ☐

(ឧបសម្ព័ន្ធសារាចរណែនាំលេខ សហវ ចុះថ្ងៃទី ខែ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

- ទីស្នាក់ការគយ និងរដ្ឋាករ Customs check point : ................................................................
- លេខកូដសំគាល់ Office code : ................................................................

- **អ្នកនាំចូល Importer** ☐ **អ្នកនាំចេញ Exporter** ☐
- នាម Name : .......................................... ភេទ Sex : ប្រុស M ☐ ស្រី F ☐
- អាស័យដ្ឋានលំអិតបច្ចុប្បន្ន Detail Actual Address : ................................................................
- អត្តសញ្ញាណប័ណ្ណ (ប្រភេទ) ID Card (Type): .................................. លេខ No. : ...................................

ចុះថ្ងៃទី Date : ........................... ចេញដោយ Issued by : ................................................

ខ្ញុំសូមប្រកាសនាំចូល/នាំចេញទំនិញដូចខាងក្រោម I declare the Import/Export Items as following :

| សំរាប់ប្រតិវេទន៍ករ For Declarant | | | | | សំរាប់មន្ត្រីគយ For Customs | | |
|---|---|---|---|---|---|---|---|
| ល.រ | មុខទំនិញ Description | ឯកតាគិត Unit | បរិមាណ Quantity | តម្លៃឯកតា Unit Value | តម្លៃគយ (R) Customs Value (R) | អត្រាពន្ធ Rate | ប្រាក់ពន្ធអាករត្រូវបង់ (R) Tax Payable (R) |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | **សរុបប្រាក់ពន្ធអាករត្រូវបង់ Total Tax Due** | ........................ |

SPECIMEN

ខ្ញុំសូមសន្យាថានឹងគោរពតាមបទបញ្ញត្តិច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។
I engage to comply with all related laws and regulations of the Kingdom of Cambodia.

**សំរាប់មន្ត្រីគយ For Customs** : បានឃើញ និងឯកភាពបណ្ដោះអាសន្នតាមការប្រកាស Seen and temporary approved as declared

- **ប្រាក់ពន្ធអាករសរុប Total Tax Payable** : ..............................................
  **ជាអក្សរ In words**:..............................................................
  ..............................................................................
- បង្កាន់ដៃពន្ធលេខ Receipt No.:............ សៀវភៅពន្ធលេខ Tax book No.:............

បានឃើញ Seen

ថ្ងៃទី...........ខែ..........ឆ្នាំ.............

ថ្ងៃទី...........ខែ.........ឆ្នាំ...........

ប្រធានស្នាក់ការគយនិងរដ្ឋាករ
Chief of Customs Checkpoint

មន្ត្រីគយត្រួតពិនិត្យ
Customs Officer

ធ្វើនៅ.................ថ្ងៃទី.........ខែ.......ឆ្នាំ...........
Due at................Date.................................

ហត្ថលេខា ស្នាមមេដៃស្ដាំប្រតិវេទន៍ករ
Declarant's signature